# គោលដៅនៃក្រុមប្រឹក្សាអប់រំ

**គោលដៅ ១ ការអាន: ភាពស្ទាត់ជំនាញ**

ចំនួនភាគរយនៃសិស្សថ្នាក់ទី ៣ ដែលប្រឡងបានពិន្ទុជាប់ ឬ ពិន្ទុលើស តាមស្តង់ដាកំរិតថ្នាក់ក្នុងមុខវិជ្ជាអក្សរសាស្ត្រអង់គ្លេសក្នុងការប្រឡង SBAC គឺនឹងកើនឡើងពី ៤៨% ក្នុងខែមិថុនា ឆ្នាំ២០២៣ ដល់ទៅ ៧០% នៅខែមិថុនា ឆ្នាំ២០២៨ បាន ។

**គោលដៅ ២ ការអាន: ពន្លឿន**

ចំនួនភាគរយនៃសិស្សថ្នាក់ទី ៤-៨ ដែលប្រឡងបានពិន្ទុ "មិនទាន់ជាប់" តាមកំរិតថ្នាក់កាលពីឆ្នាំកន្លងមក ហើយដែលពួកគេប្រឡងជាប់តាមគោលដៅរបស់ខ្នាតពិន្ទុនៃភាពលូតលាស់នៃការសិក្សា ក្នុងការប្រឡង SBAC ផ្នែកមុខវិជ្ជាអក្សរសាស្ត្រអង់គ្លេស គឺនឹងកើនឡើងពី ២៨% ក្នុងខែមិថុនា ឆ្នាំ២០២៣ ដល់ទៅ ៦០% នៅខែមិថុនា ឆ្នាំ២០២៨ បាន ។

**គោលដៅ ៣ ពិជគណិត (Algebra): ការចេះស្ទាត់ជំនាញ**

ក្នុងការស្វែងរកនូវការកើនអោយបានលើសពី ៨០% ឡើង នៃសិស្សអាមេរិកាំង ខ្មៅ ដែលប្រឡងជាប់តាមតំរូវការការទាមទារ A–G ផ្នែកពិជគណិត នៅពេលរៀនចប់ថ្នាក់ទី ៩ នោះគម្លាតខុសគ្នានៃការចេះពិជគណិតស្ទាត់រវាងសិស្សអាមេរិកាំង ខ្មៅ និងក្រុមសិស្សផ្សេងៗទាំងអស់ នឹងធ្លាក់ចុះពី ៥% ក្នុងខែមិថុនា ឆ្នាំ២០២៣ ចុះមក 0% នៅខែមិថុនា ឆ្នាំ២០២៨ បាន ។

**គោលដៅ ៤ ការត្រៀមចូលមហាវិទ្យាល័យ និង ប្រកបអាជីព**

ក្នុងការស្វែងរកនូវការកើនអោយបានលើសពី ៦៦% ឡើង នៃសិស្សអាមេរិកាំង ខ្មៅ រៀនថ្នាក់ទី ១២ ដែលមានសិទ្ធបញ្ចប់ការសិក្សាតាមថ្នាក់ A–G នោះគម្លាតខុសគ្នានៃការចេះស្ទាត់ជំនាញរវាងសិស្សអាមេរិកាំង ខ្មៅ និងក្រុមសិស្សផ្សេងៗទាំងអស់ នឹងធ្លាក់ចុះពី ១៥% ក្នុងខែមិថុនា ឆ្នាំ២០២៣ ចុះមក 0% នៅខែមិថុនា ឆ្នាំ២០២៨ បាន ។

# វិធានការទ្រទ្រង់នៃក្រុមប្រឹក្សាអប់រំ

- អគ្គនាយកមិនអាចអនុញ្ញាតអោយមានការបែងចែកធនធានឡើងវិញបានទេ ដោយគ្មានភស្តុតាងបញ្ជាក់អំពីការចែកចាយដោយមានសមធម៌ត្រឹមត្រូវរបស់ពួកគេ ដែលផ្សារភ្ជាប់ជាមួយគោការណ៍ច្បាប់សមធម៌ និងឧត្តមភាពនៃក្រុមប្រឹក្សាអប់រំនោះ ។
- អគ្គនាយកមិនអាចអនុញ្ញាតអោយមានការផ្តួចផ្តើមគំនិតធំៗនៅទូទាំងមណ្ឌលអប់រំដំណើរការទៅមុខបានឡើយ ដោយគ្មានទំនាក់ទំនងជាមួយសិស្សជនជាតិភាគតិចនិងក្រុមគ្រួសាររបស់ពួកគេជាមុនសិនទេនោះ ... ប្រព្រឹត្តតាមគោលការណ៍ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ ដែលកំពុងប្រើក្បួនអនុវត្តន៍ល្អៗដូចបានរៀបចំក្នុងពេលបច្ចុប្បន្ននេះស្រាប់ ។
- អគ្គនាយកមិនអាចអនុញ្ញាតអោយមានការអនុវត្តនូវគំរោង ឬការបង្កើតនូវកម្មវិធីសិក្សានៅក្នុងថ្នាក់ ឬកម្មវិធីផ្សេងៗណាមួយបានឡើយ បើគ្មានផ្តល់អាទិភាពលើសមធម៌ផ្នែកសិក្សានិងពូជសាសន៍នោះទេ ។

LONG BEACH
UNIFIED SCHOOL DISTRICT
*Excellence & Equity*